**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ធំ**

សំណុំរឿងរដ្ឋប្បវេណីលេខៈ ១២៧

ចុះថ្ងៃទី.០៥-១០-២០១១

សាលក្រមលេខៈ ១៤ "ឆ"

ចុះថ្ងៃទី ០៧-១២-២០១១

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ធំ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

នាថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១១

**ចៅក្រមជំនុំជំរះ**

- លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ធំ

**ក្រឡាបញ្ជីសវនាការ**

- លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ធំ

-ដើមបណ្ដឹងឈ្មោះ [redacted] **ហៀវីឌី** ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរមុខរបរៈមន្ត្រីអាជ្ញាធរអប្សរា ទីលំនៅសព្វថ្ងៃនៅភូមិខ្នា ឃុំជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ប្រពន្ធឈ្មោះ [redacted] លីណា កូន០៣នាក់ ឪពុកឈ្មោះ [redacted] គីមហ៊ួន "រ" ម្ដាយឈ្មោះ [redacted] ឆេង អ៊ី "រ" ។

-ចុងចំលើយឈ្មោះ [redacted] **តៃ** ភេទប្រុស អាយុ៦៣ឆ្នាំ ជាតិខ្មែរ មុខរបរៈ ធ្វើស្រែ ទីលំនៅសព្វថ្ងៃនៅភូមិប្រមាត់ដី ឃុំ ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ប្រពន្ធឈ្មោះ [redacted] ឡូត កូន០៩នាក់ ឪពុកឈ្មោះ [redacted] ទូច "ស" ម្ដាយឈ្មោះ [redacted] សៀង "ស" ។

## អង្គហេតុ និងចំណុចវិវាទ

**១-ការទាមទាររបស់ដើមបណ្ដឹង :**

**-ដើមចោទបានប្ដឹងថា :** សុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោមៈ

-សុំទាមទារប្រាក់ជំពាក់ចំនួន ៤.៤០០ ដុល្លា "បួនពាន់បួនរយដុល្លា" និងការប្រាក់៣%ក្នុងមួយខែ ។

-ថ្លៃខាតបង់ពេលវេលានិងជម្ងឺចិត្តចំនួន ៤លានរៀល ។

-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

**អង្គហេតុដែលជាមូលហេតុនៃការទាមទារ:** ឈ្មោះ ហ៊ុល តៃ បានខ្ចីលុយពីឈ្មោះ [redacted] ហៀវីឌី ចំនួន៣លើក ដែលមានធ្វើកិច្ចសន្យាដូចខាងក្រោមៈ -កិច្ចសន្យាលើកទី១ ចុះថ្ងៃទី០៨-០៦-២០១០ ខ្ចីប្រាក់ចំនួន ២០០០ដុល្លា ។

-កិច្ចសន្យាលើកទី២ ចុះថ្ងៃទី០៩-០៦-២០១០ ខ្ចីប្រាក់ចំនួន ២០០០ដុល្លា ។

-កិច្ចសន្យាលើកទី៣ ចុះថ្ងៃទី២៥-០៦-២០១០ ខ្ចីប្រាក់ចំនួន ៤០០ដុល្លា ។

សរុបទឹកប្រាក់ដែលខ្ចីចំនួន ៤.៤០០ដុល្លា ដើម្បីរកស៊ីទិញលក់ដីហ៊ុនគ្នា-បានផលចំណេញចែកគ្នាជាមួយឈ្មោះ [redacted] ឆេងអ៊ី

Scanned with CamScanner

និងឈ្មោះ [redacted] លីណា ជាប្រពន្ធដើមចោទឈ្មោះ [redacted] ហ្សឺឌី ។ ដោយពេលនោះម្ចាស់ដីសោមសូត្រគេទាមទារឱ្យកក់ចំនួន ១ម៉ឺនមួយពាន់ដុល្លា តែចុងចម្លើយឈ្មោះ [redacted] តែ គាត់គ្មានលុយដាក់ហ៊ុននិងគេក៏ធ្វើកិច្ចសន្យាផ្ដិតមេដៃខ្ចីពីហេងហ្សឺឌី ទាំង៣លើកគ្រប់ពេលដែលត្រូវប្រគល់លុយឱ្យសោមសូត្រទាំង៣លើកដែរ ។ តែក្រោយពីពេលកក់ដីមកម៉្មយចិនដែលថាគេមកទិញដីនោះគេមិនបានមកទេរហូតមកដល់សព្វថ្ងៃ ដែលធ្វើឱ្យប្រាក់កក់នោះដាច់ទៅលើម្ចាស់ដី ទើបឈ្មោះ [redacted] ហ្សឺឌី ប្ដឹងទាមទារប្រាក់ដែលឈ្មោះ [redacted] តែ ខ្ចីនោះមកវិញព្រមទាំងការប្រាក់៣%មួយខែ និងទាមទារជម្ងឺចិត្តចំនួន៤លានរៀលផង ។

**២-ការអះអាងរបស់គូភាគី:**

**-ដើមចោទឈ្មោះ [redacted] ហ្សឺឌីបានថ្លែងការណ៍ថា:** ខ្ញុំប្ដឹងសុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោម:

- សុំទាមទារប្រាក់ដើមសរុបចំនួន៤.៤០០ដុល្លានិងការប្រាក់៣%ក្នុងមួយខែ ។
- ទាមទារជម្ងឺចិត្តចំនួន ៤លានរៀល ។
- ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

**អង្គហេតុដែលជាមូលហេតុនៃការទាមទារគឺ :** ឈ្មោះ [redacted] តែបានខ្ចីប្រាក់ខ្ញុំចំនួន៣លើកគឺ:

-លើកទី១នៅថ្ងៃទី០៨-០៦-២០១០ហ៊ុលតែខ្ចីប្រាក់ចំនួន២០០០ដុល្លាដោយមានកិច្ចសន្យាភ្ជាប់ ។

-លើកទី១នៅថ្ងៃទី០៩-០៦-២០១០ហ៊ុលតែខ្ចីប្រាក់ចំនួន២០០០ដុល្លាដោយមានកិច្ចសន្យាភ្ជាប់ ។

-លើកទី១នៅថ្ងៃទី២៥-០៦-២០១០ហ៊ុលតែខ្ចីប្រាក់ចំនួន៤០០ដុល្លាដោយមានកិច្ចសន្យាភ្ជាប់ ។

សរុបទឹកប្រាក់ [redacted] តែ ខ្ចីទាំង៣លើកមានចំនួន ៤.៤០០ដុល្លា សហរដ្ឋអាមេរិក

ដោយហេតុថាឈ្មោះ [redacted] តែ គាត់មិនគោរពតាមកិច្ចសន្យាខាងលើទេគាត់បង់ការប្រាក់បានតែ២ខែចំនួន២៥០ដុល្លា ខ្វះ១៤ដុល្លានិងខ្វះថ្លៃសេវា៦ដុល្លាទៀតសរុប២០ដុល្លារួចកឈប់បង់រហូតមក ។ គឺកាលណោះឈ្មោះ [redacted] តែគាត់រកស៊ីកក់ដេរដីហ៊ុនគ្នាជាមួយម្ដាយខ្ញុំឈ្មោះ [redacted] ឆេងអ៊ី ដីនោះមានចំនួន១៣៧៨.៥៣០ហិកតា ស្ថិតនៅក្នុងភូមិទូលគ្រើល ស្រុកប្រាសាទបល្ល័ង្គ ដែលមានតំលៃ ៣២០ដុល្លា/១ហិកតា ។ឈ្មោះហ៊ុលតែនិងម្ដាយខ្ញុំគាត់ទៅទាក់ទងជាមួយក្រុមហ៊ុនចិនថាគេរកទិញដីឈ្មោះ [redacted] តែ គាត់នាំម្ដាយខ្ញុំទៅសៀមរាបដើម្បីជួបម្ចាស់ដី ឈ្មោះ [redacted] សូត្រ។ទាមទារប្រាក់កក់ចំនួន១ម៉ឺនដុល្លាទើបគេប្រគល់សិទ្ធិឱ្យគាត់លក់ដីនោះ ទើបគាត់ឱ្យខ្ញុំជួយរកលុយឱ្យគាត់ផង ខ្ញុំសួរបញ្ជាក់ថា យើងហ៊ានកក់ប្រាក់ឱ្យគេតើថៅកែចិននោះពិតប្រាកដថាទិញដីនោះមែនឬទេ ឈ្មោះ [redacted] តែ គាត់ថា ច្បាស់ហើយមួយអាទិត្យគេមកកក់លុយហើយ ខ្ញុំថាមានតែខ្ចីលុយគេទេ ហើយឱ្យការគេផងគាត់ក៏ព្រម ។ខ្ញុំក៏ខ្ចីលុយម្ដាយមីងខ្ញុំចំនួន១ម៉ឺនដុល្លា ប្រគល់ឱ្យសោមសូត្រដោយចែកហ៊ុនគ្នាម្ដាយខ្ញុំ៤៥០០ដុល្លា [redacted] តែ ៤៥០០ដុល្លា និងប្រពន្ធខ្ញុំក៏សុំចូល២០០០ដុល្លា ដែរដោយឮគាត់ថា៧ថ្ងៃទៀតគេមកកក់លុយហើយនោះក្រែងបានចំណេញនិងគេដែរ ។ ក្រោយមករហូស៧ថ្ងៃហើយមិន ឃើញថៅកែចិនមកឮថាឈឺ គាត់និងម្ដាយខ្ញុំក៏ទៅសុំពន្យារពេលបន្តសិទ្ធិលក់ដីនោះពីសោមសូត្រចំនួន១ខែទៀតសោម សូត្រ ក៏ទារ១០០០ដុល្លាទៀត ឈ្មោះ [redacted] តែ បានធ្វើកិច្ចសន្យាខ្ចីប្រាក់ពីខ្ញុំចំនួន ៤០០ដុល្លាទៀត ម្ដាយខ្ញុំចេញ៤០០ដុល្លាដែរ ខ្ញុំក៏ចេញ១០០ដុល្លាដែរ ។ ប្រាក់ខ្ចីទាំង៣លើកនោះគាត់សន្យាសងការប្រាក់៣%ក្នុងមួយខែ តែគាត់បង់បានតែ២ខែចំនួនប្រាក់២៥០ដុល្លាតែប៉ុណ្ណោះក៏ឈប់បង់រហូតមកទើបខ្ញុំប្ដឹងទាមទារឱ្យសងប្រាក់ដើមចំនួន៤៤០០ដុល្លាអាមេរិកនិងការប្រាក់៣%ក្នុងមួយខែ ព្រមទាំងជម្ងឺចិត្តចំនួន៤លានរៀល ។ ដែលការអះអាងខាងលើខ្ញុំមានឯកសារភស្តុតាងកិច្ចសន្យាខ្ចីប្រាក់ទាំង៣លើក និងកិច្ចសន្យាទំនុកចិត្តទាំង៣លើកនិងតារាងបង់ការប្រាក់ប្រចាំខែព្រមទាំងសាក្សីចំនួន៤នាក់គឺឈ្មោះ មិត្តសន ឈ្មោះ [redacted] ឆេងអ៊ី ឈ្មោះ [redacted] ឡី ឈ្មោះ



Scanned with CamScanner

ខាន់ លីណា ឈ្មោះ[redacted]ផន និងឈ្មោះ [redacted] សូត្រ ដែលបានដាក់ជូនតុលាការរួចមកហើយ ។

**-ចុងចម្លើយឈ្មោះ [redacted] តៃ បានថ្លែងតបថា:** ចំពោះការលើកឡើងរបស់ដើមចោទ:

-ទាមទារប្រាក់ដើម ៤៤០០ដុល្លា បដិសេធមិនទទួលស្គាល់ទេ ខ្ញុំទទួលស្គាល់តែខ្ចៅដៃខ្ញុំតែ២៤០០ដុល្លា ទេ ដែលពីមុនខ្ញុំទទួលស្គាល់៣៤០០ដុល្លាគឺបើលក់ដីដាច់ខ្ញុំសងទាំងដើមទាំងការ៣៤០០ដុល្លានោះ ។

-ទាមទារជម្ងឺចិត្ត៤លានរៀល បដិសេធ

-ប្រាក់ប្រដាប់ក្តីក៏បដិសេធដែរ ។

ដោយហេតុថា ខ្ញុំខ្ចីមានកិច្ចសន្យាលើកទី១ធ្វើនៅផ្ទះដើមចោទចុះថ្ងៃទី០៨-០៦-២០១០ខ្ញុំទទួលស្គាល់ថាចំនួនប្រាក់ខ្ចី ២០០០ដុល្លា និងគិតការប្រាក់ ៣%ក្នុងមួយខែ បើថៅកែទិញដី ។ កិច្ចសន្យាលើកទី២ធ្វើនៅថ្ងៃទី ០៩-០៦-២០១០ ចំនួនទឹកប្រាក់ ២០០០ដុល្លា ខ្ញុំមិនទទួលស្គាល់ទេព្រោះខ្ញុំមិនបានផ្តិតមេដៃទេសុំបដិសេធ ។ កិច្ចសន្យាទី៣ធ្វើនៅថ្ងៃទី២៥-០៦-២០១០ ទទួលស្គាល់ប្រាក់៤០០ដុល្លាមែន ។ ចំពោះការប្រាក់ដែលខ្ញុំបង់២ខែនោះគឺខ្ញុំគ្រាន់តែជួយបង់ឱ្យ២ខែនោះព្រោះថៅកែគេមិនមកយកដីនោះ បើឱ្យខ្ញុំបង់ការរាល់ខែនោះខ្ញុំគ្មានលុយបង់ទេ ។ខ្ញុំទទួលស្គាល់ថាជំពាក់២៤០០ដុល្លា ពីមុនមកដែលខ្ញុំទទួលស្គាល់ថា៣៤០០ដុល្លានោះបើសិនលក់ដីដាច់ទើបខ្ញុំបង់ទាំងដើមទាំងការឱ្យ៣៤០០ដុល្លានោះ បើលក់មិនដាច់ខ្ញុំគ្មានលុយបង់ឱ្យទេ ។ខ្ញុំមានសាក្សីឈ្មោះប៊ូឡូត និង ឈ្មោះ [redacted] ណំ ដែលបានដាក់ជូនតុលាការរួចមកហើយ ។ ឯសាក្សីក្នុងរឿងខ្ចីប្រាក់នេះខ្ញុំគ្មានទេ ព្រោះខ្ញុំទៅតែម្នាក់ឯងមានតែឈ្មោះ [redacted] សូត្រ ដែលសព្វថ្ងៃនៅក្នុងពន្ធនាគារខេត្តសៀមរាប ។

**-ដើមចោទឈ្មោះ [redacted] ហៀវអ៊ី បានអះអាងតបថា:** ចំពោះកិច្ចសន្យាលើកទី២នេះគាត់ធ្វើជាមួយប្រពន្ធខ្ញុំនៅផ្ទះខ្ញុំជាមួយម្តាយខ្ញុំឈ្មោះ [redacted] ឆេងអ៊ី ធ្វើនៅថ្ងៃទី ០៩-០៦-២០១០ គឺសោមសូត្រទាមទារឱ្យកក់១ម៉ឺនដុល្លា ដើម្បីយកលិខិតផ្ទេរសិទ្ធិឱ្យតាតែនិងម្តាយខ្ញុំលក់ដីឱ្យចិនថ្ងៃទី០៩៨-០៦-២០១០ បានប្រគល់ឱ្យសោមសូត្រ ៥០០០ដុល្លាម្តងហើយ និងប្រគល់បន្ថែម៥០០០ដុល្លា ម្តងទៀតនៅថ្ងៃទី ០៩-០៦-២០១០ ទើបមានធ្វើកិច្ចសន្យាលើកទី២នេះ ខ្ចីប្រាក់ចំនួន ២០០០ដុល្លាទៀត ដែលមានម្តាយខ្ញុំជាសាក្សី ព្រោះពេលប្រគល់លុយឱ្យ [redacted] សូត្រ ទាំង២លើកក្នុងម្តង៥០០០ដុល្លានោះ គឺចែកគ្នាចេញម្តាយខ្ញុំ២០០០ដុល្លា ខ្ញុំ១០០០ដុល្លា និង ហ៊ុលតៃ ២០០០ដុល្លា ដូច្នេះហើយទើបមានកិច្ចសន្ទះហើយទើបមានកិច្ចសន្យាទាំង២លើកនោះ មានខ្ចីប្រាក់ ២០០០ដុល្លាដូចគ្នា ។ នៅពេលធ្វើកិច្ចសន្យាលើកទី២នោះតាតៃគាត់ថាមិនបាច់ធ្វើកិច្ចសន្យាក៏បានដែរ តែល្ងាចចិនគេវេលុយកក់១០ម៉ឺនដុល្លា មកឱ្យហើយ តែប្រពន្ធខ្ញុំថា លុយណាទ្រា ត្រូវតែធ្វើកិច្ចសន្យាឱ្យខ្ញុំជាស់អាង ប្រពន្ធខ្ញុំក៏សសេរកិច្ចសន្យារួចឱ្យ [redacted] តៃ ផ្តិតមេដៃដោយមានម្តាយខ្ញុំឈ្មោះ [redacted] ឆេងអ៊ី សាក្សីផង ។

**-ចុងចម្លើយឈ្មោះ [redacted] តៃបានអះអាងតបថា:** ខ្ញុំមិនបានផ្តិតមេដៃលើកិច្ចសន្យាលើកទី២ទេ ។ ក្រោយពីកក់លុយលើកទី១រួច មានធ្វើកិច្ចសន្យាលើកទី២មែន តែឈ្មោះ ខាន់លីណាថាកែលេខលើកិច្ចសន្យាលើកទី១ តែគាត់កែឬមិនកែខ្ញុំមិនដឹងទេ ។

**-សាក្សីឈ្មោះ ខាន់លីណាបានអះអាងតបថា:** [redacted] តៃ គាត់ជាអ្នកឱ្យខ្ញុំកែលេខតែខ្ញុំមិនកែទេ ត្រូវតែធ្វើកិច្ចសន្យាបន្ថែមហើយបានប្រាប់គាត់ថាខ្ញុំសសេរខាងខ្នងកិច្ចសន្យាពីមុន ធ្វើក្រោយកិច្ចសន្យាលើកទី១មួយថ្ងៃគឺថ្ងៃទី០៩-០៦-២០១០ ប្រគល់លុយឱ្យសោមសូត្រនៅថ្ងៃធ្វើកិច្ចសន្យានោះវេលាម៉ោង៤ល្ងាច ។

**-សាក្សីឈ្មោះ [redacted] ឆេងអ៊ីបានអះអាងថា:** យើងរកស៊ីតក់ដេរដីចង់បានឯកសារដីពីម្ចាស់ដីដើម្បីយកទៅលក់ឱ្យថៅកែចិនខ្លួនឯង ទើបសុខចិត្តកក់លុយឱ្យម្ចាស់ដីសោមសូត្រចំនួន០១ម៉ឺនដុល្លា តាមការទាមទាររបស់គេ ។ ប្រាក់មួយម៉ឺននោះចែកគ្នា

ចេញដំបូងថាៈតាតែ៣០០០ដុល្លា ខ្ញុំ៣០០០ដុល្លា កូនប្រសារខ្ញុំខាន់លីណា ២០០០ដុល្លា និងអេសប៉េចិន២០០០ដុល្លាដែរ តែដល់ម៉ោង ៣-៤ល្ងាចហើយមិនឃើញអេសប៉េចិនយកលុយមកទេ តាតែគាត់ថាជិតម៉ោងបួនត្រូវប្រគល់លុយឱ្យគេហើយអ៊ីឯងចេញ១ពាន់ទៅ ខ្ញុំចេញ១ពាន់ដែរខំហួសពេលទៅយកឯកសារហើយ ទើបឱ្យកូនប្រសារខ្ញុំខាន់លីណាធ្វើកិច្ចសន្យានោះទៅ។ កូនខ្ញុំវាខ្ចីលុយម្ដាយ មីង ឈ្មោះ សៀង - លើកទី១ចំនួន៥០០០ដុល្លា ខ្ញុំធ្វើកិច្ចសន្ធសន្យាខ្ចី២០០០ដុល្លា តាតែ ២០០០ដុល្លា កូនប្រសារខ្ញុំ១០០០ដុល្លា។

- លើកទី២ចំនួន៥០០០ដុល្លា ខ្ញុំធ្វើកិច្ចសន្ធសន្យាខ្ចី២០០០ដុលា តាតែ ២០០០ដុល្លា កូនប្រសារខ្ញុំ១០០០ដុល្លា។

- លើកទី៣អង្វរម្ចាស់ដីឱ្យគេពន្យាពេលឱ្យមួយខែទៀតដោយថៅកែចិនឈី [redacted] សូត្រ ទារ១០០០ដុល្លាទៀតខ្ញុំ ថា ចេញ២នាក់គាត់ ៥០០ដុល្លាម្នាក់ទៅតែគាត់មិនព្រមទេគាត់ទាមទារឱ្យកូនប្រសារខ្ញុំខាន់លីណាចេញ១០០ដុល្លា គាត់៤០០ដុល្លា និងខ្ញុំ ៤០០ដុល្លា ដែលលុយក្រោយនេះគាត់ធ្វើកិច្ចសន្យាខ្ចីមកឱ្យកូនខ្ញុំ។ ចំពោះកិច្ចសន្យាទី២ ដំបូងគាត់ថាឱ្យកែកិច្ចសន្យាទី១មែន តែកូន ខ្ញុំថា ទ្រាលុយណា ត្រូវតែធ្វើកិច្ចសន្យាឱ្យបានច្បាស់លាស់កូនខ្ញុំសសេរខ្ទង់កិច្ចសន្យាទី១ ធ្វើនៅផ្ទះកូនខ្ញុំ ហើយឱ្យ [redacted] តែ គាត់ផ្តិត មេដៃពិតមែន ដោយដាក់ខ្ញុំធ្វើជាសាក្សី។

**-សាក្សីឈ្មោះ** [redacted] **ណាំ បានអះអាងថាៈ** ខ្ញុំដឹងតែថាគាត់ទាំង២នាក់រកស៊ីហ៊ុនដីជាមួយគ្នាពិតមែនព្រោះឃើញ ឈាង ឆេងអ៊ី គាត់ទៅស្នាក់នៅផ្ទះតាតែឯភូមិប្រមាត់ដី តែខ្ញុំមិនបានដឹងពីរឿងលុយកាក់ដែលខ្ចីនៅឯសៀមរាបទេ។

**-សាក្សីឈ្មោះ** [redacted] **ឡូត អះអាងថាៈ** ខ្ញុំដឹងតែថាគាត់រកស៊ីដីហ៊ុនគ្នាមែនតែប្តីខ្ញុំគាត់ទៅឡើងទៅសៀមរាបខ្ចីលុយ នោះមិនដឹងទេ។

**-សាក្សីឈ្មោះ** [redacted] **សន បានអះអាងថាៈ** ខ្ញុំដឹងថាគាត់រកស៊ីដីហ៊ុនគ្នាមែនលុះគ្មានលុយកក់ដើម្បីយកលិខិតផ្ទេរសិទ្ធិ ក្នុងរយៈពេលមួយអាទិត្យឈ្មោះ លីណាក៏ទៅរកលុយគេ៥០០០ដុល្លាមកប្រគល់ឱ្យសោមសូត្រលើកទី១ ហើយបើស្អែកឡើងមិនបាន ៥០០០ដុល្លា មកប្រគល់ឱ្យគេទៀតទេ គេហែកលិខិតផ្ទេរសិទ្ធិនោះចោល ហើយប្រាក់៥០០០ដុល្លានោះ គេមិនសងទៀត ទើបលីណា ទៅរកលុយគេ៥០០០ដុល្លាទៀត។ ឯភាគហ៊ុនមានតែ៣នាក់ទេ [redacted] តែ និង [redacted] ឈេងអ៊ី ស្មើគ្នាឯលីណា តិចជាងគេ ។ ខ្ញុំដឹងថាបាន ប្រគល់លុយឱ្យ [redacted] សូត្រ ២លើកម្តង៥០០០ដុល្លា លុយលើកទី៣ចំនួន១០០០ដុល្លាមិនដឹងទេខ្ញុំជិះឡានជាមួយសោមសូត្រព្រោះ សោមសូត្រឱ្យខ្ញុំរៀបដីឱ្យគាត់នៅស្វាយធំ។

**ចំណុចគ្មានវិវាទៈ**

-កិច្ចសន្យាចុះថ្ងៃទី០៨-០៦-២០១០ ខ្ចីប្រាក់ចំនួន២០០០ដុល្លាចុងចម្លើយទទួលស្គាល់ថាបានផ្តិតមេដៃមែន។

-កិច្ចសន្យាចុះថ្ងៃទី២៥-០៦-២០១០ ខ្ចីប្រាក់ចំនួន៤០០ដុល្លា ចុងចម្លើយទទួលស្គាល់ថាបានផ្តិតមេដៃមែន។

**ចំណុចវិវាទៈ**

-កិច្ចសន្យាចុះថ្ងៃទី ០៩-០៦-២០១០ ខ្ចីប្រាក់ចំនួន២០០០ដុល្លា ចុងចម្លើយថាមិនបានផ្តិតមេដៃទេ ខ្លួនមិនទទួល ស្គាល់ទេ។

-ចុងចម្លើយថាមិនមានធ្វើកិច្ចសន្យាលើកទី២ទេ ដោយ ខាន់លីណាថាគ្រាន់តែកែលេខលើកិច្ចសន្យាលើកទី១ បាន ហើយ។ តែខាន់លីណាថាៈខ្លួនមិនបាននិយាយថាកែលេខទេ គឺ [redacted] តែ ទេដែលនិយាយថាឱ្យកែលេខទៅ តែខ្លួននិយាយថាលុយណា ទ្រាត្រូវតែធ្វើកិច្ចសន្យាឱ្យខ្ញុំឱ្យបានច្បាស់លាស់ទើបខ្លួនសសេរខ្ទង់កិច្ចសន្យាលើកទី១ទៅ។

-ចំពោះកាលបរិច្ឆេទបង់ប្រាក់និងការប្រាក់៣%នោះដើមចោទទាមទារឱ្យបង់តាមកិច្ចសន្យាតែចុងចម្លើយសុំបង់នៅ



Scanned with CamScanner

ពេលលក់ដីដាច់។

-ទាក់ទងនិងភាគហ៊ុនដើមចោទថា:មាន៣នាក់គឺ: ម្តាយដើមចោទ ប្រពន្ធដើមចោទនិងចុងចម្លើយ ។ ឯចុងចម្លើយថាមាន៤នាក់គឺ: ម្តាយដើមចោទ ប្រពន្ធដើមចោទ ចុងចម្លើយ និងអេសប៉េចិន "ថៅកែទិញដី" ។

-ប្រាក់ប្រដាប់ក្តីដើមចោទទាមទារឱ្យចុងចម្លើយបង់ តែចុងចម្លើយមិនព្រមបង់ឱ្យទេ ។

## សំអាងហេតុ

-ទាក់ទងចំណុចវិវាទចុងចម្លើយអះអាងថា ខ្លួនមិនបានបង្កើតកិច្ចសន្យាលើកទី២ចុះថ្ងៃទី០៩-០៦-២០១០ដែលមានទឹកប្រាក់២០០០ដុល្លាទេ នៅក្នុងរឿងនេះខ្លួនមានសាក្សីចំនួន០២នាក់ដាក់មកតុលាការ តែតាមពិតនៅពេលសួរដេញដោលសាក្សីមិនបានដឹងពីរឿងខ្ចីប្រាក់នោះទេ ។ជាងនេះទៀតនៅពេលធ្វើសេចក្តីថ្លែងការណ៍ចុងចម្លើយបានអះអាងថាខ្លួន ពិតជាមានកិច្ចសន្យាលើកទី២មែន តែគ្រាន់តែខ្លួនមិនបានផ្តិតមេដៃលើកិច្ចសន្យានោះទេ ដូច្នេះខ្លួនមិនទទួលខុសត្រូវទេ ។ ចំណុចនេះបញ្ជាក់ឱ្យឃើញថាការអះអាងរបស់ចុងចម្លើយគ្មានមូលដ្ឋានអ្វីច្បាស់លាស់ទេ គ្រាន់តែប្រកែកមិនព្រមសងតែប៉ុណ្ណោះ ។ ចំណែកដើមចោទ អះអាងថា នៅថ្ងៃទី ០៩-០៦-២០១០ ពិតជាមានបង្កើតកិច្ចសន្យាលើកទី២មែនដែលមានទឹកប្រាក់ចំនួន២០០០ដុល្លា ជាក់ស្តែងមានកិច្ចសន្យាជាភស្តុតាងស្រាប់ដែលការអះអាងនេះវាស្របជាមួយការលើកឡើងរបស់សាក្សីឈ្មោះខាន់ លីណា ជាប្រពន្ធដើមចោទនិងឈ្មោះ [redacted] ឆេងអ៊ី ជាម្តាយរបស់ដើមចោទដែលអះអាងថានៅថ្ងៃទី ០៩-០៦-២០១០ ពិតជាមានបង្កើតកិច្ចសន្យាពិតប្រាកដមែន ។ ភស្តុតាងប្រយោលមួយទៀតដែលអាចបញ្ជាក់ថា ការបង្កើតកិច្ចសន្យានោះ គឺការប្រគល់លុយដែលតាមការអះអាងរបស់ចុងចម្លើយឈ្មោះ [redacted] តែ ក៏បានបញ្ជាក់ថា ពិតជាមានការប្រគល់លុយ៣ដងមែន ដែលចំណុចនេះអាចឱ្យតុលាការជឿថាកិច្ចសន្យាលើកទី២ ចុះថ្ងៃទី០៩-០៦-២០១០ ពិតជាមានពិតប្រាកដមែន ។

-ចំពោះការអះអាងរបស់ចុងចម្លើយថា ក្នុងកិច្ចសន្យាប្រាក់១១.០០០ដុល្លានោះមានភាគហ៊ុនចំនួន៤នាក់គឺ: ខ្លួនម្តាយដើមចោទ ប្រពន្ធដើមចោទ និងអេសប៉េចិន ប៉ុន្តែខ្លួនមិនមានសាក្សីឬភស្តុតាងអ្វីបញ្ជាក់ដែលអាចឱ្យតុលាការជឿបានឡើយ ។ចំណែកដើមចោទអះអាងថា:មានភាគហ៊ុន ចំនួនតែ៣នាក់ទេគឺ: ម្តាយខ្លួនចំនួន៤៥០០ដុល្លា ចុងចម្លើយចំនួន៤៥០០ដុល្លា និងប្រពន្ធខ្លួនចំនួន២០០០ដុល្លា នោះគឺមានសាក្សីឈ្មោះ[redacted]សន ជាសាក្សី ហើយជាក់ស្តែងពេលប្រគល់លុយកក់មានតែភាគហ៊ុន៣នាក់មែនមិនមានវត្តមានអេសប៉េចិនឡើយ ។ ចំណុចនេះមានមូលដ្ឋានគ្រប់គ្រាន់អាចឱ្យតុលាការជឿបានថា ភាគហ៊ុនក្នុងការកក់ប្រាក់ថ្លៃដីឱ្យ ឈ្មោះ [redacted]សូត្រ មានតែ៣នាក់ពិតមែន ដែលក្នុងនោះឈ្មោះ ខាន់លីណា ជាប្រពន្ធដើមចោទទទួលខុសត្រូវចំនួន២០០០ដុល្លា ចុងចម្លើយទទួលខុសត្រូវចំនួន៤៥០០ដុល្លា និងឈ្មោះឈាងឆេងអ៊ីជាម្តាយដើមចោទទទួលខុសត្រូវចំនួន៤៥០០ដុល្លាមែន ។តុលាការគួរសម្រេចឱ្យចុងចម្លើយសងតាមចំនួនទឹកប្រាក់ភាគហ៊ុនក្នុងកិច្ចសន្យាខាងលើ ដែលស្ថិតក្នុងចំណែកទទួលខុសត្រូវរបស់ខ្លួនគឺប្រាក់ដើមចំនួន ៤៤០០ ដុល្លា ។

-យល់ឃើញថាកិច្ចសន្យាលើកទី១ចុះថ្ងៃទី០៩-០៦-២០១០ និងកិច្ចសន្យាលើកទី៣ចុះថ្ងៃទី២៥-០៦-២០១០ ដែលមានទឹកប្រាក់សរុបចំនួន២.៤០០ដុល្លា ដើមចោទនិងចុងចម្លើយបានទទួលស្គាល់ថាមានពិតមែនដែល តុលាការអាចយកជាមូលដ្ឋានក្នុងការសម្រេចសេចក្តីបាននិងគួរសម្រេចប្រកាសអនុញ្ញាតឱ្យអនុវត្តបណ្តោះអាសន្នបាន ។

-យល់ឃើញថាចំពោះកិច្ចសន្យាលើកទី២ចុះថ្ងៃទី២៥-០៦-២០១០ ដែលមានទឹកប្រាក់២០០០ដុល្លានោះចុងចម្លើយឈ្មោះ[redacted] តែ ទទួលស្គាល់ថាមានមែនតែខ្លួនមិនបានផ្តិតមេដៃទេ តុលាការអាចយកជាមូលដ្ឋានក្នុងការសម្រេចសេចក្តីបាន ។ ម្យ៉ាង

ទៀតដើមចោទមានឯកសារគ្រប់គ្រាន់ហើយថែមទាំងមានសាក្សីឈ្មោះ ឈាងឆេងអ៊ី និងឈ្មោះ ខាន់លីណា បានផ្ដិតមេដៃលើ ឯកសារនោះផង ។

- យល់ឃើញថា ចំពោះអត្រាការប្រាក ៣% ក្នុង១ខែ ដែលចុងចម្លើយឈ្មោះ [redacted] តែ បដិសេធនោះតែចំណុចនេះ តុលាការពិនិត្យ ឃើញថា សុទ្ធតែមានចែងក្នុងកិច្ចសន្យាទាំង៣លើក យ៉ាងច្បាស់លាស់ ហើយចុងចម្លើយធ្លាប់បានបង់ការប្រាក់២ខែ ទៀតផងនេះ អាចបញ្ជាក់ថាពិតជាមានការព្រមព្រៀងគ្នាក្នុងការកំណត់អត្រាការប្រាក់ក្នុងកិច្ចសន្យាខាងលើដូចការអះអាងរបស់ ដើមចោទ គឺការប្រាក់ចំនួន៣% ក្នុង១ខែ ចំណុចនេះតុលាការគួរយកជាមូលដ្ឋានក្នុងការសម្រេចសេចក្ដីតាមច្បាប់ ។

-យល់ឃើញថា អត្រាការប្រាក់ដែលមានចុះក្នុងកិច្ចសន្យាទាំង៣លើកមានចំនួន៣% ក្នុង១ខែ លក្ខខ័ណ្ឌត្រង់ចំណុចដែល មានចែងក្នុងកិច្ចសន្យាទាំង០៣ខាងលើ មានខ្លឹមសារផ្ទុយនិងមាត្រា ៥៩ នៃក្រឹត្យច្បាប់ លេខៈ៣៨ ក្រ.ច ស្ដីពីកិច្ចសន្យា និងការ ទទួលខុសត្រូវក្រៅកិច្ចសន្យា ដូច្នេះតុលាការគួរសម្រេចតាមច្បាប់ ។

-យល់ឃើញថា ចំពោះប្រាក់ប្រដាប់ក្ដី ដែលដើមចោទបានបង់រួចហើយនោះ ដើមចោទទាមទារឱ្យចុងចម្លើយបង់សង វិញ តុលាការគួរសម្រេចតាមផ្លូវច្បាប់ ។

-យល់ឃើញថា ចំពោះការទាមទារថ្លៃខាតបង់ពេលវេលាចំនួន ៤បួនលានរៀល តុលាការគួរសម្រេចតាមស្ថានភាពជាក់ស្ដែង ។

## **សេចក្ដីសម្រេចបញ្ចប់**

១-សម្រេចឱ្យ**ឈ្មោះ**[redacted]**តៃ** សងប្រាក់ដើមចំនួន **២.៤០០ដុល្លា "បួនពាន់បួនរយដុល្លា "** អាមេរិក ទៅឱ្យឈ្មោះ [redacted] **ហៀវ៉ីឌី** តាមកិច្ចសន្យាចុះថ្ងៃទី០៨-០៦-២០១០ និងកិច្ចសន្យាចុះថ្ងៃទី២៥-០៦-២០១០។ សេចក្ដីសម្រេចត្រង់ចំណុចទី១នេះ អាចអនុវត្តជាបណ្ដោះអាសន្នបាន។

២-សម្រេចឱ្យ**ឈ្មោះ** [redacted] **តៃ** សងប្រាក់ដើមចំនួន **២.០០០ដុល្លា"ពីពាន់ដុល្លា"**អាមេរិកទៅឱ្យ**ឈ្មោះ**[redacted]**ហៀវ៉ីឌី** តាមកិច្ចសន្យាចុះថ្ងៃទី០៩-០៦-២០១០ ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

៣-សម្រេចឱ្យឈ្មោះ[redacted] **តៃ** សងការប្រាក់ ៥% ក្នុងមួយឆ្នាំលើកប្រាក់ដើមសរុប **៤.៤០០ដុល្លា "បួនពាន់បួនរយដុល្លា"** អាមេរិក ទៅឱ្យឈ្មោះ[redacted] **ហៀវ៉ីឌី** គិតចាប់ពីថ្ងៃទី ០៩-០៦-២០១០ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន តាមមាត្រា៥៩ នៃ ក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច ស្ដីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

៤-សម្រេចឱ្យឈ្មោះ [redacted] តៃ សងប្រាក់ថ្លៃខាតបង់ពេលវេលាចំនួន **២.៥០០.០០០រៀល"ពីរលានប្រាំសែនរៀល"** ទៅឱ្យឈ្មោះ **ហេង ហៀវ៉ីឌី** ចាប់ពីសាលក្រមស្ថាពរតទៅ ។

៥-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

៦-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១១ ចំពោះភាគីចុងចម្លើយ កំបាំងមុខដើមចោទចាត់ទុកជាចំពោះមុខ។ ទុកសិទ្ធប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប ។

**ចៅក្រមជំនុំជំរះ**

[redacted]